ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សេចក្តីប្រកាសព័ត៌មាន

ថ្មីៗនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទទួលរបាយការណ៍ថា មានការនាំត្បូងឈើដែលមានប្រភពពីព្រៃធម្មជាតិទៅបរទេស។ ចំពោះករណីនេះ ក្រសួងសូមរំលឹកថា ការនាំត្បូងឈើដែលមានប្រភពពីព្រៃធម្មជាតិចេញទៅបរទេសត្រូវបានហាមឃាត់តាមរយៈមាត្រា៣ នៃអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីយថាប្រភេទផល អនុផលព្រៃឈើអនុញ្ញាតឱ្យនាំចេញ នាំចូល។

អាស្រ័យហេតុនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់រដ្ឋបាលព្រៃឈើ និងអង្គភាពក្រោមឱវាទទាំងអស់ ឱ្យធ្វើការសហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី-ខេត្ត ដើម្បីពិនិត្យ តាមដាន និងទប់ស្កាត់សកម្មភាពនាំចេញទៅបរទេសនូវត្បូងឈើដែលមានប្រភពពីព្រៃធម្មជាតិនេះ ដោយមនសិការទទួលខុសត្រូវខ្ពស់បំផុត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax : (855) 23 - 217 320